# សេចក្ដីណែនាំសម្រាប់ឪពុកម្ដាយ/អាណាព្យាបាល លើស្ដង់ដារនិងការវាយតម្លៃនៃការត្រៀមខ្លួនរួចរាល់សម្រាប់ចូលសិក្សានៅសាកលវិទ្យាល័យនិងបម្រើការងារ



## តើត្រូវធ្វើដូចម្ដេច ដើម្បីត្រៀមខ្លួនសម្រាប់ជីវិតក្រោយពីចប់មធ្យមសិក្សា ?

យើងអាចគិតដូចកីឡាករដែលត្រូវការដឹងថាតើពេលណាត្រូវសម្ដែង ឬអ្នកតូរ្យតន្ត្រីដែលត្រូវចេះអានអក្សរភ្លេង ឬអ្នកសាងសង់ដែលត្រូវការគម្រោងស្ថាបត្យកម្មមុនពេលចាប់ផ្ដើមសាងសង់។ បច្ចុប្បន្ននេះ សិស្សានុសិស្សកំពុងទទួលបានចំណេះដឹងដើម្បីត្រៀមខ្លួនចូលទៅក្នុងសាកលវិទ្យាល័យ និងចូលបម្រើការងារ។ នេះមានន័យថាពួកគេនឹងដើរចូលទៅក្នុងថ្នាក់រៀននៅសាកល-វិទ្យាល័យ កន្លែងធ្វើការ ឬកម្មវិធីបណ្ដុះបណ្ដាលណាមួយ ជាមួយនឹងវិធីសាស្ត្រដែលអាចដោះស្រាយបញ្ហានានាស្ទើរតែទាំងអស់ចាប់តាំងពីថ្ងៃទីមួយ។

## តើអ្វីទៅជាវិធីសាស្ត្រដើម្បីទទួលបានជោគជ័យ ?

សិស្សានុសិស្សដែលមានមូលដ្ឋានរឹងមាំសម្រាប់ចូលរៀននៅសាកលវិទ្យាល័យ ឬចូលបម្រើការងារ នឹងមានកម្រិតជំនាញនៅក្នុងចំណេះដឹងសំខាន់ៗ ក្នុងការសិក្សា ហើយទទួលបានចំណេះដឹងនៅក្នុងការអនុវត្ត កត្តាទាំងអស់នេះហើយនឹងជួយពួកគេឆ្លងកាត់ពីជីវិតនៅវិទ្យាល័យទៅកាន់សាកលវិទ្យាល័យ ឬការបម្រើការងារ។ អ្នកអប់រំនៅក្នុងរដ្ឋរបស់អ្នកបានពិពណ៌នាអំពីជំនាញទាំងនោះនៅពេលដែលពួកគេបានបង្កើតនិយមន័យនៃការត្រៀមខ្លួនឱ្យបានរួចរាល់ សម្រាប់ការសិក្សានៅសាកល-វិទ្យាល័យ និងការចូលបម្រើការងារ។

## តើស្ដង់ដារនៃការត្រៀមខ្លួនរួចរាល់សម្រាប់ចូលសិក្សានៅសាកលវិទ្យាល័យ និងការចូលបម្រើការងារមានអ្វីខ្លះ ?

រដ្ឋជាង៤០បានអនុម័តនូវស្ដង់ដារសិក្សាថ្មី ដែលផ្ដោតសំខាន់ទៅលើជំនាញក្នុងការគិតបែបស៊ីជម្រៅ ការដោះស្រាយបញ្ហា និងការផ្ដល់ហេតុផល ទៅដល់សិស្សានុសិស្សដែលត្រូវការសម្រាប់ពិភពលោកនាពេលបច្ចុប្បន្ន។  គេបានទទួលស្គាល់វាថាជាស្ដង់ដារស្នូលរួមរបស់រដ្ឋ ស្ដង់ដារទាំងនោះបានពិពណ៌នាអំពីជំនាញ និងចំណេះដឹងដែលសិស្សានុសិស្សត្រូវតែចេះនៅគ្រប់ថ្នាក់នៃភាសាអង់គ្លេស និងគណិតវិទ្យា។ ស្ដង់ដារថ្មីនេះ ត្រូវការឱ្យមានការប្រឡងថ្មី ដើម្បីឱ្យស៊ីគ្នាជាមួយនឹងជំនាញដែលត្រូវបង្រៀននៅក្នុងថ្នាក់។ ការប្រឡងនេះត្រូវបានកំណត់ថាជាការត្រួតពិនិត្យការសិក្សា ជួយដល់គ្រូបង្រៀន  និងឪពុកម្ដាយឱ្យដឹងពីការរីកចម្រើនរបស់សិស្សា-នុសិស្ស និងការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់។  ការប្រឡងនេះត្រូវបានរៀបចំឡើងសម្រាប់ជំនួសការប្រឡងភាសាអង់គ្លេស និងគណិតវិទ្យានៅទូទាំងរដ្ឋ។

សម្រាប់ព័ត៌មានបន្ថែមអំពីស្ដង់ដារស្នូលរួម សូមចូលទៅកាន់៖
*www.corestandards.org*



Smarter Balanced
Assessment Consortium



## ការវាយតម្លៃរបៀបនៃការថ្លឹងថ្លែងដ៏វៃឆ្លាត

សមាគមវាយតម្លៃថ្លឹងថ្លែងដ៏វៃឆ្លាត គឺជាក្រុមរដ្ឋដែលប្រមូលផ្តុំអ្នកអប់រំ និងអ្នកជំនាញផ្សេងទៀតរួមគ្នាដើម្បីអភិវឌ្ឍការប្រឡងដែលមានគុណ-ភាពខ្ពស់ ត្រឹមត្រូវទៅតាមស្តង់ដារស្នូលរួមរបស់រដ្ឋ។ រដ្ឋ និងអ្នកអប់រំ បានអភិវឌ្ឍនូវការប្រឡងថ្មីៗ ដោយមានគោលដៅជាការផ្តល់នូវកម្រិតនៃការព័ត៌មានកាន់តែស៊ីជម្រៅទៅដល់គ្រូបង្រៀន និងឪពុកម្តាយដើម្បីគាំទ្រដល់ការសិក្សារបស់សិស្សានុសិស្ស។ គ្រូបង្រៀនត្រូវដឹងអំពីរបៀបនៃការធ្វើការរបស់សិស្សានុសិស្សដើម្បីរៀនឱ្យចេះជំនាញដ៏លំបាកនេះ។ ការប្រឡងនេះជួយប្រាប់ពីរបៀបនៃការណែនាំរបស់គ្រូបង្រៀន ដើម្បីឱ្យពួកគេអាចកែប្រែការបង្រៀន ហើយអាចបំពេញតាមតម្រូវការរបស់សិស្សានុសិស្សទាំងអស់។

សម្រាប់ព័ត៌មានបន្ថែមអំពីការវាយតម្លៃថ្លឹងថ្លែងដ៏វៃឆ្លាត
សូមចូលទៅកាន់៖
*www.smarterbalanced.org*

## ធនធាន

### តើពេលណាដែលខ្ញុំអាចទទួលបានព័ត៌មានបន្ថែមដើម្បីជួយកូនខ្ញុំ ?

សូមទៅសាលារៀនកូនរបស់អ្នក ហើយនិយាយទៅកាន់គ្រូបង្រៀនកូនរបស់អ្នក ឬនាយកសាលា
ពិនិត្យមើលព័ត៌មាននៅលើគេហទំព័រដូចខាងក្រោម៖

- ការរក្សាទុកស្នូលសំខាន់ៗ
  *achievethecore.org*
- សមាគមគ្រូបង្រៀនមាតាបិតាជាតិ
  *National Parent Teacher Association*
  *www.pta.org*
- ក្លាយជាវីរៈបុរសសិក្សាមួយ (ការថ្លឹងថ្លែងដ៏វៃឆ្លាតសម្រាប់)
  *bealearninghero.org*

